# តើហេតុអ្វី បានជាអ្នកត្រូវបារម្ភ អំពីមេរោគវុស្តណាល (West Nile Virus)?

- មេរោគវិស្តណាល(West Nile Virus) អាចធ្វើឲ្យគ្រួសាររបស់អ្នកឈឺបាន ។
- មេរោគវិស្តណាល អាចឆ្លងរាលដាលដោយសារសត្វមូស ។
- អ្នកឆ្លងមេរោគវិស្តណាលដោយសារមូសខាំ ។
- អ្នកអាចឈឺនៅ 3 –15 ថ្ងៃ បន្ទាប់ពីមូសបានខាំអ្នក ។
- មនុស្សដែលឈឺដោយសារមេរោគនេះ អាចមានអាការដូចជាគ្រុនផ្តាសាយធំ ។ គេអាចមាន :
    - គ្រុន
    - ឈឺក្បាល
    - ឈឺខ្លួនប្រាណ
    - កន្ទួលសាច់
- មនុស្សមួយចំនួនដែលមានមេរោគវិស្តណាល អាចឈឺខ្លាំង ហើយអាចស្លាប់ផង ។
- ភាគច្រើននៃមនុស្សដែលឈឺខ្លាំង គឺជាមនុស្សមានអាយុប្រហែល 50 ឆ្នាំ ឬចាស់ជាង ប៉ុន្តែមនុស្សគ្រប់ៗរូបត្រូវការដឹងអំពីមូស ទាំងឡាយ ហើយការពារកុំឲ្យវាមកជិតខ្លួន។ ។

បើសិនជាអ្នកមានសំណួរអ្វី
ទូរស័ព្ទទៅគ្រូពេទ្យរបស់អ្នក ឬមន្ទីរពិនិត្យ

ដើម្បីឲ្យបានជ្រាបការពិតថែមទៀត សូមទៅមើល :

City of Long Beach
Department of Health and Human Services

**www.longbeach.gov/health/WNV_info**

ក្រសួងសុខាភិបាល រដ្ឋកាលីហ្វ័រនញ៉ា
California Department of Health Services
**www.westnile.ca.gov**

មជ្ឈមណ្ឌលសំរាប់ត្រួតពិនិត្យ និងបង្ការជំងឺ
Centers for Disease Control and Prevention
**www.cdc.gov/ncidod/dvbid/westnile/**

**KHMER VERSION**

# ចូរប្រយុទ្ធការពារនឹងសត្វមូសកំណាច!



**ចូរការពារខ្លួនអ្នក និងគ្រួសាររបស់អ្នក ពីមេរោគវិស្ត ណាល វីរុស** *(West Nile Virus)*

ដើម្បីឲ្យបានជ្រាបពត៌មានថែមទៀត :

www.longbeach.gov/health/WNV_info
(562)570-4128

## តើអ្នកអាចធ្វើអ្វី?

ត្រូវជៀសវាងកុំឲ្យមូសខាំ!



មូសតែងខាំនៅពេលព្រឹកព្រលឹម
និងនៅពេលព្រលប់ៗ ។

នៅពីរម៉ោងបន្ទាប់ពីថ្ងៃលិច គឺជាពេលមូសខាំខ្លាំង
ជាងគេបង្អស់ ។



បើអ្នកចេញទៅក្រៅនៅម៉ោង
នេះ ត្រូវស្លៀកខោជើងវែង
និងពាក់អាវដៃវែង ។

ត្រូវប្រើថ្នាំបាញ់កំចាត់មូសមានសារធាតុ ឌីត
(DEET) ផង ដែរ ។
បាញ់ថ្នាំកំចាត់មូសនៅលើស្បែករបស់អ្នក
ដែលមិនបានគ្របបាំងដោយសំលៀកបំពាក់ ។

ថ្នាំបាញ់កំចាត់មូសដែលមានសារធាតុ
ឌីត (DEET)
រក្សាកុំឲ្យមូសខាំអ្នក ។



ត្រូវធ្វើតាមសេចក្តីពន្យល់ណែនាំ
ដោយប្រុងប្រយ័ត្ន ។

## ចូររក្សាផ្ទះសំបែងរបស់អ្នកឲ្យបានសុខ!



មូសតែងតែពង និងញាស់ធំឡើង
នៅក្នុងទីដែលមានទឹកដក់ ។

វាប្រើពេលតែ 7 ថ្ងៃប៉ុណ្ណោះ
ដែលពងមូសចាប់ផ្តើមញាស់
ហើយក្លាយជាមូសពេញវ័យ ។

ត្រូវកំចាត់កុំឲ្យមានទីទឹកដក់
នៅជុំវិញផ្ទះរបស់អ្នក ។

ត្រូវចាក់ទឹកចេញពីធុង ពីកង់
ឡានចាស់ៗ ពីថូដាំផ្កា និងពី
ប្រដាប់ប្រដាក្មេងលេង ។



ត្រូវប្តូរទឹកក្នុងចានសំរាប់ឲ្យសត្វផឹក
និងឲ្យសត្វស្លាបងូត រៀង
រាល់ពីរបីថ្ងៃម្តង ។

ត្រូវរក្សាសំណាញ់បង្អួច និងទ្វារកុំឲ្យរហែក ។

សំណាញ់ រក្សាកុំឲ្យមូសចូលបាន ។

## ចូរប្រាប់មិត្តភ័ក្តិរបស់អ្នក និង អ្នកជិតខាងរបស់អ្នក!



មេរោគវីរុស្តណាល ឥឡូវនេះគេ
បានរកឃើញនៅពាសពេញរដ្ឋកាលី-
ហ្វ័រនញ៉ា ។

បក្សីដែលងាប់ គឺជាសញ្ញាថាមាន
មេរោគវីរុស្តណាល នៅក្នុង
តំបន់ដែលអ្នករស់នៅ ។





បក្សីដូចជាសត្វក្អែក ចំពូកក្អែករឿន
និងល្ញាចេក ឈឺជាខ្លាំង ហើយអាច
ងាប់ដោយសារវីរុស្តណាលវីរុស ។

អ្នកមិនឆ្លងមេរោគវីរុស្តណាល
ដោយសារការប៉ះនឹងសត្វងាប់ទេ ។





ដើម្បីត្រួតពិនិត្យមើលការឆ្លងរាលដាល
នៃវីរុស រដ្ឋក៏កំពុងតាមដានសត្វងាប់ ។

**ដើម្បីរាយការណ៍អំពីសត្វងាប់ សូមចូលមើល**
www.westnile.ca.gov
ឬទូរស័ព្ទទៅលេខឥតចេញថ្លៃ
**(562)570-4128**